អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
អគ្គនាយកដ្ឋានស្រាវជ្រាវ
នាយកដ្ឋានស្រាវជ្រាវថវិកា

# ព្រឹត្តិបត្រព័ត៌មានថវិកា និងសេដ្ឋកិច្ច

## មាតិកា៖

- លំហូរចូល ទុនវិនិយោគផ្ទាល់ពីបរទេស មកកម្ពុជាកើនឡើង ៩,៦%គិតត្រឹម ឆមាសទី១ នៃឆ្នាំ២០២១
- រដ្ឋមន្ត្រីពាណិជ្ជកម្ម លើកទឹកចិត្តឱ្យសហគ្រិន ធ្វើសាជីវកម្មដោយផ្សារភ្ជាប់ ការទទួលខុសត្រូវផ្នែកសង្គម
- រោងចក្រផលិតស្កររំពៅខេត្តក្រចេះ ដំណើរការឡើងវិញ
- តើមេរោគ អូមីក្រុងនឹងជះឥទ្ធិពលយ៉ាងណាខ្លះ ទៅលើគោលដៅស្តារវិស័យទេសចរណ៍កម្ពុជា ?
- កំណើនពាណិជ្ជកម្មបរទេសវៀតណាម កើន ១៨,៥% នៅខែវិច្ឆិកា
- បំណុលប្រជាជនថៃ កើនដល់៨៩,៣% នៃផ.ស.ស
- ទំហំពាណិជ្ជកម្មកម្ពុជា និងឥណ្ឌូនេស៊ី សម្រេចបានជាង៥១៣លានដុល្លារ ក្នុងរយៈពេល១០ខែឆ្នាំនេះ
- ការប្រមូលចំណូលមិនមែនសារពើពន្ធពីវិស័យរ៉ែ កើនឡើងជាង ២៧%ក្នុងរយៈពេល៩ខែដើមឆ្នាំ២០២១
- ថ្នាក់ដឹកនាំធនាគារកណ្តាលវៀតណាម លើកសរសើរពីវឌ្ឍនភាពនៃវិស័យធនាគារនៅកម្ពុជា
- អង្គការសហប្រជាជាតិបាននិយាយថា ទស្សនៈវិស័យកំណើនពាណិជ្ជកម្មពិភពលោកឆ្នាំ២០២២ មានភាពមិនច្បាស់លាស់
- កូវីដបំប្លែងថ្មី Omicron គំរាមកំហែងដល់សេដ្ឋកិច្ចរបស់សហរដ្ឋអាមេរិក និងពិភពលោក
- OPEC+ ទំនងជាមានភាពប្រុងប្រយ័ត្នខ្លាំងចំពោះផែនការបង្កើនទិន្នផលប្រេងនៅកិច្ចប្រជុំសប្តាហ៍នេះ
- ឯកអគ្គរដ្ឋទូតឆែកសន្យាជំរុញវិនិយោគិន មកបណ្តាក់ទុននៅកម្ពុជា


ពិនិត្យ និងកែសម្រួលដោយ

- សួន ពុធថាវី អគ្គនាយិកា នៃអគ្គនាយកដ្ឋានស្រាវជ្រាវ
- គឹម សុចិត្រា អគ្គនាយករង នៃអគ្គនាយកដ្ឋានស្រាវជ្រាវ
- ណុប ចាន់ធី ប្រធាននាយកដ្ឋានស្រាវជ្រាវថវិកា
- ម៉ែន ខែមរៈ អនុប្រធាននាយកដ្ឋានស្រាវជ្រាវថវិកា



រៀបរៀងដោយនាយកដ្ឋានស្រាវជ្រាវថវិកា សប្តាហ៍ទី២ ខែធ្នូ ឆ្នាំ២០២១ លេខ ៖ ៩៦

# ព័ត៌មាន និងទិន្នន័យអំពីប្រទេសកម្ពុជា

## លំហូរចូល ទុនវិនិយោគផ្ទាល់ពីបរទេស មកកម្ពុជាកើនឡើង ៩,៦%គិតត្រឹម ធមាសទី១ នៃឆ្នាំ២០២១



*ប្រភព៖ khmertimes, ២០២១ រូបភាព៖ ជរ សុគន្ធា*

យោងតាមទិន្នន័យស្ថិតិរបស់ធនាគារជាតិនៃកម្ពុជា បានបញ្ជាក់ថា ប្រទេសកម្ពុជាបានទាក់ទាញការវិនិយោគផ្ទាល់ពីបរទេស (FDI)ចំនួន ៣៩ប៊ីលានដុល្លារ គិតត្រឹមធមាសទី១ ឆ្នាំ២០២១ ដែលកើនឡើង ៩,៦% ធៀបនឹងរយៈពេលដូចគ្នានៃឆ្នាំមុន។

ប្រភពនៃការវិនិយោគដោយផ្ទាល់ពីបរទេស ដែលមានទំហំធំជាងគេសម្រាប់កម្ពុជា គឺប្រទេសចិន ដែលបានចុះបញ្ជី មានទឹកប្រាក់ចំនួន ១៧,៣ប៊ីលានដុល្លារ សមាមាត្រនឹង ៤៤,២%នៃទុនវិនិយោគ ដែលបានចុះបញ្ជីសរុប រួមទាំងអាជ្ញាប័ណ្ណថ្មីៗដ៏ទៃទៀត។

សម្រាប់ប្រទេសកូរ៉េខាងត្បូង និងប្រទេសវៀតណាមជាប្រភពធំបន្ទាប់ពីចិន ដែលមានដើមទុនចុះបញ្ជី ៤,១ប៊ីលានដុល្លារ និង ២,៥ប៊ីលានដុល្លាររៀងគ្នា។ ទន្ទឹមនឹងនេះ ប្រទេសសិង្ហបុរី ជប៉ុន ម៉ាឡេស៊ី ថៃ អង់គ្លេស កាណាដា និងសហរដ្ឋអាមេរិក ក៏ជាប្រទេសដែលមានការវិនិយោគច្រើននៅកម្ពុជាផងដែរ។

ទុនវិនិយោគ(FDI)ជារួមមានអាជ្ញាប័ណ្ណ ជាចម្បងទៅលើផ្នែកហិរញ្ញវត្ថុ ការផលិត អចលនទ្រព្យ សណ្ឋាគារ និងភោជនីយដ្ឋាន កសិកម្ម អគ្គិសនី និងសំណង់។

រាជរដ្ឋាភិបាលកម្ពុជាបានលើកទឹកចិត្តដល់អ្នកវិនិយោគ តាមរយៈការផ្តល់ភាពជាម្ចាស់ក្រុមហ៊ុនបរទេស ១០០% ថ្ងៃឈប់សម្រាកពន្ធសាជីវកម្ម អត្រាពន្ធសាជីវកម្ម ២០% បន្ទាប់ពីរយៈពេលលើកទឹកចិត្តបានបញ្ចប់ ការនាំចូលទំនិញមូលធនដោយមិនបង់ពន្ធ និងគ្មានការរឹតបន្តឹងលើការធ្វើមាតុភូមិនិវត្តន៍ដើមទុន៕ *ដោយ សេន ចន្ទូ*

*ប្រភព៖khmertimes.ចេញផ្សាយថ្ងៃទី២៩ខែវិច្ឆិកា ឆ្នាំ២០២១*

## រដ្ឋមន្ត្រីពាណិជ្ជកម្ម លើកទឹកចិត្តឱ្យសហគ្រិន ធ្វើសាជីវកម្មដោយផ្សារភ្ជាប់ ការទទួលខុសត្រូវផ្នែកសង្គម




ក្នុងពិធីប្រគល់ពានរង្វាន់សាជីវកម្មទទួលខុសត្រូវផ្នែកសង្គម (CSR) ឆ្នាំ២០២១ ដែលរៀបចំដោយសភាពាណិជ្ជកម្មអឺរ៉ុបប្រចាំកម្ពុជា នៅល្ងាចថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០២១ រដ្ឋមន្ត្រីពាណិជ្ជកម្ម បានលើកឡើងថា ការទទួលខុសត្រូវផ្នែកសង្គមរបស់សាជីវកម្មពីសំណាក់សហគ្រិនវ័យក្មេង ធុរជន មីក្រូសហគ្រាស សហគ្រាសខ្នាតមធ្យម វិនិយោគិន និងបណ្តាអ្នកពាក់ព័ន្ធនៅក្នុង

សង្គម ជាកត្តាដ៏សំខាន់ក្នុងការចូលរួមចំណែកអភិវឌ្ឍប្រទេស និងសង្គមកម្ពុជា ប្រកបដោយទំនួលខុសត្រូវ និរន្តភាព និងបរិយាប័ន្ន។ រាជរដ្ឋាភិបាលកម្ពុជាដែលមានក្រសួងពាណិជ្ជកម្មជាសេនាធិការ បានយកចិត្តទុកដាក់គាំទ្រ និងលើកកម្ពស់សកម្មភាពធុរៈកិច្ចដែលទទួលខុសត្រូវផ្នែកសង្គម នៅកម្ពុជា។ ជាក់ស្តែង ក្រសួងពាណិជ្ជកម្ម សម្រេចបាននូវបទដ្ឋានគតិយុត្តសំខាន់ៗជាច្រើន ក្នុងពេលថ្មីៗនេះរួមមាន ៖ ការផ្តល់សច្ចាប័នលើច្បាប់ស្តីពីការប្រកួតប្រជែង, ច្បាប់ស្តីពីកិច្ចការពារអ្នកប្រើប្រាស់ និងបទបញ្ញត្តិថ្មីៗដទៃទៀតពាក់ព័ន្ធនឹងយន្តការគាំទ្រដល់សាជីវកម្មទទួលខុសត្រូវផ្នែកសង្គម CSR។ រដ្ឋមន្ត្រីពាណិជ្ជកម្ម ក៏បានលើកទឹកចិត្តឱ្យមានអ្នកចូលរួមបន្ថែមទៀតពីសំណាក់សហគ្រិនជាតិ និងអន្តរជាតិ ក្នុងកិច្ចការ CSR ក៏ដូចជាការចូលរួមសហការពីដៃគូអភិវឌ្ឍន៍នានា ឱ្យបានច្រើនថែមមួយកម្រិតទៀត៕ *ដោយ ម៉ែន ខែមរៈ*

*ប្រភព ៖ freshnewsចេញផ្សាយថ្ងៃទី ២៤ ខែវិច្ឆិកា ឆ្នាំ២០២១។*

## ការប្រមូលចំណូលមិនមែនសារពើពន្ធពីវិស័យរ៉ែ កើនឡើងជាង ២៧%ក្នុងរយៈពេល៩ខែដើមឆ្នាំ២០២១




*ប្រភព៖ ភ្នំពេញប៉ុស្តិ៍ ២០២១ រូបភាព៖ ក្រសួងរ៉ែ និងថាមពល*

យោងតាម ឯកឧត្តម អ៊ឹង ឌីប៉ូឡា អគ្គនាយកដ្ឋានធនធានរ៉ែនៃក្រសួងរ៉ែ និងថាមពល បានបង្ហាញថា៖ ក្នុងរយៈពេល៩ខែដើមឆ្នាំ២០២១ កម្ពុជាប្រមូលចំណូល មិនមែនសារពើពន្ធពីវិស័យរ៉ែបានប្រមាណជា ៩៨,៥ប៊ីលានរៀល ស្មើនឹង ២៤,២១លានដុល្លារ កើនឡើង ២៧%ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ២០២០។ ចំណូលប្រមូលបាននេះ គឺស្មើនឹង ៩៦% នៃច្បាប់ថវិកាឆ្នាំ២០២១។

ក្រោមការបើកឱ្យដំណើរការឡើងវិញស្ទើរគ្រប់វិស័យ បន្ទាប់ពីបានទទួលភាពជោគជ័យពីយុទ្ធនាការចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ និងការចាប់ផ្តើមបើកប្រទេសឡើងវិញនៅប្រទេសដ៏ទៃទៀតជាសញ្ញាវិជ្ជមាននៃការកម្រើកឡើងវិញនៃសេដ្ឋកិច្ច។ ជាមួយនឹងភាពវិជ្ជមាននេះក្រសួងរ៉ែ និងថាមពលអាចវាយតម្លៃបានថា ចំណូលមិនមែនសាពើពន្ធពីវិស័យរ៉ែ និងមានកាកើនឡើងនៅក្នុងឆ្នាំ២០២២ និងឆ្នាំបន្តបន្ទាប់ ដោយសារតម្រូវការរ៉ែសំណង់នៅក្នុងវិស័យសំណង់នឹងកើនឡើង ចំណែកបរិមាណផលិតរ៉ែមាសអាចផលិតបានពេញលេញទៅតាមផែនការដែលបានគ្រោងក្នុងឆ្នាំ២០២២ ខាងមុខនេះ ស្របពេលដែលការនាំចេញថ្មអារ ក៏ត្រូវបានព្យាករណ៍ថានឹងកើនឡើងផងដែរ។

បន្ថែមពីនេះ ចំណូលមិនមែនសារពើពន្ធពីវិស័យរ៉ែ គឺជាផ្នែកមួយនៃចំណូលមិនមែនសាពើពន្ធផ្សេងទៀត ដែលចូលរួមចំណែកនៅក្នុងកំណើនសេដ្ឋកិច្ចកម្ពុជា។

នៅក្នុងឆ្នាំ២០២២ ក្រសួងរ៉ែ គ្រោងនឹងដាក់ផែនការនៃការប្រមូលចំណូលមិនមែនសាពើពន្ធពីវិស័យរ៉ែ ថានឹងមានចំនួន ១៤០,៨ប៊ីលានរៀល កើនឡើង ៣៧%បើធៀបនឹងច្បាប់ថវិកាឆ្នាំ២០២១។ *ដោយ មុំ ចិន្តា*

*ប្រភព៖ភ្នំពេញប៉ុស្តិ៍ ចេញផ្សាយថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ២០២១*

## កសិករខេត្តឧត្តរមានជ័យ ចាប់ផ្តើមសំរុកដាំដុះដំណាំដំឡូងមី ខណៈតម្លៃល្អប្រសើរ




*ដោយ news.btv*

កសិករនៅស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ បានចាប់ផ្តើមដាំដំឡូងមី ខណៈរដូវនេះតម្លៃដំឡូងមីកំពុងឡើងថ្លៃល្អប្រសើរ។ កសិករម្នាក់មានវ័យជាង៥០ឆ្នាំ បានឱ្យដឹងថា គ្រួសាររបស់គាត់ប្រកបមុខរបរធ្វើកសិកម្មអស់រយៈពេលជិត២០ឆ្នាំមកហើយ អាស្រ័យដោយការធ្វើស្រែ និងដាំដំឡូងមី។ ការដាំដំឡូងមីនេះភាគច្រើនតែងតែផ្តល់ផលបានល្អប្រសើរ ជាងការធ្វើស្រែ ព្រោះពេលប្រមូលផលម្តងៗ តម្លៃឡើងខ្ពស់ ក្នុងរយៈពេលប៉ុន្មានឆ្នាំនេះ។ ពេលខ្លះ ក្រុមឈ្មួញមកចាំទទួលទិញដល់កន្លែងក៏មាន ដឹកទៅលក់បន្តនៅប្រទេសជិតខាងដូចជា ប្រទេសថៃ នឹងវៀតណាមជាដើម។ លោកបន្តថា ទោះបី វិបត្តិកូវីដ-១៩ មិនទាន់បញ្ចប់ទាំងស្រុងក្តី ក៏លោកមិនសូវបារម្មណ៍ឡើយ ព្រោះថាតម្លៃដំឡូងលើទីផ្សារបច្ចុប្បន្នហាក់បីដូចជាមិនធ្លាក់នោះឡើយ គឺតម្លៃលក់ចេញឱ្យឈ្មួញ នៅតែឡើងខ្ពស់៕

*ដោយ ម៉ែន ខែមរៈ*

*ប្រភព ៖ news.btv ចេញផ្សាយថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០២១។*

## រោងចក្រផលិតស្ករអំពៅខេត្តក្រចេះ ដំណើរការឡើងវិញ



*រូបភាព៖ រដ្ឋបាលខេត្តក្រចេះ*

រោងចក្រផលិតស្ករអំពៅ ស្ថិតនៅក្នុងឃុំអូរគ្រៀង ស្រុកសំបូរ ខេត្តក្រចេះ កំពុងរៀបចំដំណើរការសង្វាក់ផលិតកម្មឡើងវិញ ក្រោយពីបានផ្អាកផលិតកម្មនាឆ្នាំ២០០៨ ដោយសារជួបវិបត្តិក្ស័យធន។ រោងចក្រនេះគ្រោងដាក់ដំណើរការនៅខែធ្នូខាងមុខ ក្រោមការវិនិយោគរបស់ក្រុមហ៊ុនកាមេដេនូវេឈ័រ របស់វៀតណាមសហការជាមួយក្រុមហ៊ុនកសិកម្មយុវជនស្វាយរៀង។

រោងចក្រនេះ មានសមត្ថភាពផលិតស្ករអំពៅក្នុងបរិមាណ១ម៉ឺន៥ពាន់តោន ក្នុងមួយឆ្នាំ។ ជាជំហានដំបូង ក្រុមហ៊ុនបានដាំអំពៅលើផ្ទៃដី៣ពាន់ហិកតា ត្រៀមប្រមូលផលសម្រាប់ផលិតកម្មស្ករអំពៅ នៅខែធ្នូខាងមុខនេះ។ ក្រុមហ៊ុនក៏មានផែនការដាំដុះបន្ថែមឱ្យបាន១ម៉ឺនហិកតាទៅថ្ងៃខាងមុខ ។ ការបើកដំណើរការឡើងវិញ គឺដើម្បីផលិតស្ករអំពៅសម្រាប់ទីផ្សារក្នុងស្រុក និងនាំចេញទៅបរទេស។

ឯកឧត្តមអភិបាលខេត្តក្រចេះ ក៏បានស្នើឱ្យក្រុមហ៊ុនបង្កើនទុនវិនិយោគបន្ថែម និងធ្វើយ៉ាងណាប្រើប្រាស់ដីឱ្យអស់លទ្ធភាព ដើម្បីបង្កើតជាពហុប្រយោជន៍ឱ្យអស់សក្តានុពល។

ការដំណើរការរោងចក្រផលិតស្ករអំពៅ រួមចំណែកយ៉ាងសំខាន់ ក្នុងលើកស្ទួយជីវភាពប្រជាពលរដ្ឋខេត្ត

ក្រចេះ អាចកាត់បន្ថយការធ្វើចំណាកស្រុក របស់ប្រជាពលរដ្ឋ។ *ដោយ ម៉ែន ខែមរៈ*
*ប្រភព៖ខេមបូណ្ឌមីស ចេញផ្សាយថ្ងៃទី២៦ខែវិច្ឆិកា ឆ្នាំ២០២១។*

## តើមេរោគ អូមីក្រុងនឹងជះឥទ្ធិពលយ៉ាងណាខ្លះ ទៅលើគោលដៅស្តារវិស័យទេសចរណ៍កម្ពុជា?



*ដោយ ខេមបូណ្ឌមីស*

ការផ្ទុះការឆ្លងរាលដាលនៃជំងឺកូវីដ-១៩បំប្លែងថ្មី អូមីក្រុងនៅតំបន់អាហ្វ្រិក កំពុងបង្កក្តីបារម្ភថ្មីបន្ថែមទៀតដល់ពិភពលោក ស្របពេលមេរោគចាស់ៗនៅមិនទាន់ផុតរលត់ពីភពផែនដីនៅឡើយ។

សម្រាប់ប្រទេសកម្ពុជាវិញ មេរោគបំប្លែងខ្លួនថ្មីនេះ ក៏បង្កក្តីបារម្ភដល់ផែនការស្តារវិស័យទេសចររបស់កម្ពុជាផងដែរ។ មេរោគបំប្លែងថ្មីនេះ ជាការគំរាមកំហែងថ្មីមួយទៀតសម្រាប់វិស័យទេសចរណ៍កម្ពុជា ទោះបីមេរោគនេះ មិនទាន់មានវត្តមាននៅកម្ពុជាក៏ដោយ។ ប្រតិបត្តិករទេសចរណ៍ អាចប្រឈមនឹងការខាតបង់កាន់តែធ្ងន់ធ្ងរ ប្រសិនបើមេរោគបំប្លែងថ្មីនេះធ្វើឱ្យរាំងស្ទះដល់ការធ្វើដំណើររបស់ភ្ញៀវទេសចរបរទេស ដែលមានបំណងចូលមកកម្ពុជា ខណៈពេលដែលប្រត្តិករបានចំណាយថវិកាយ៉ាងច្រើន លើការរៀបចំហេដ្ឋារចនាសម្ព័ន្ធ និងកន្លែងរកស៊ីរបស់ពួកគេឡើងវិញ ត្រៀមទទួលទេសចរបរទេសចាក់វ៉ាក់សាំងរួច ដែលរំពឹងថានឹងមកនៅចុងឆ្នាំ២០២១ ឬដើមឆ្នាំ២០២២។ ស្របពេលទេសចរណ៍ផ្ទៃក្នុងចាប់ផ្តើមកំរើកឡើងវិញសន្សឹមៗបន្ទាប់ពីបើកប្រទេសឡើងវិញ និងការលើកលែងការធ្វើចត្តាឡីស័កចំពោះអ្នកដំណើរចូលមកកម្ពុជាដែលបានចាក់វ៉ាក់សាំងកូវីដ-១៩ រួចមិនបានប៉ុន្មានផង ស្រាប់តែមានវត្តមានមេរោគកូវីដ-១៩ បំប្លែងខ្លួនថ្មីអូមីក្រុងមួយបន្ថែមទៀត។ ប្រទេសមួយចំនួនលើពិភពលោក បានរឹតបន្តឹងវិធានការ និងបិទការហោះហើរពីប្រទេសមានហានិភ័យមួយចំនួន។ ជាក់ស្តែងប្រទេសមួយចំនួននៅតំបន់អាស៊ានមានដូចជា ហ្វីលីពីន ឥណ្ឌូណេស៊ី ថៃ និងសិង្ហបុរីជាដើម ក៏បានបិទជើងហោះពីប្រទេសអាហ្វ្រិក និងប្រទេសអឺរ៉ុបមួយចំនួន ដើម្បីទប់ស្កាត់មេរោគបំប្លែងខ្លួនថ្មីនេះផងដែរ។ *ដោយ ម៉ែន ខែមរៈ*
*ប្រភព៖ខេមបូណ្ឌមីសចេញផ្សាយថ្ងៃទី៣០ខែវិច្ឆិកាឆ្នាំ២០២១។*

## តារាងប្រចាំសប្តាហ៍

### តារាងទី១៖ ចំណូលពន្ធលើពាណិជ្ជកម្មក្រៅប្រទេសក្នុងរយៈពេល៨ខែ ឆ្នាំ២០២១

ទិន្នន័យរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុកម្ពុជា បង្ហាញថានៅក្នុងរយៈពេល៨ខែ ឆ្នាំ២០២១នេះ រដ្ឋបាលថ្នាក់ជាតិ បានប្រមូលចំណូលពន្ធលើពាណិជ្ជកម្មក្រៅប្រទេសសរុបចំនួន ១ ៣៤១, ៦៧ប៊ីលានរៀល បានធ្លាក់ចុះប្រមាណជា ១៤,១% បើធៀបនឹងរយៈពេលដូចគ្នា ឆ្នាំមុន។

ជាក់ស្តែង ការប្រមូលចំណូលពន្ធ និងអាករលើការនាំចូលបានសរុបចំនួន ១ ៣១៤, ៧៧ប៊ីលានរៀល នៅក្នុងរយៈពេល៨ខែ ឆ្នាំ២០២១ បានធ្លាក់ចុះប្រហែលជា ១៥,១% បើធៀបនឹងរយៈពេលដូចគ្នា ឆ្នាំមុន។

ក៏ប៉ុន្តែ ការប្រមូលចំណូលពន្ធ និងអាករលើការនាំចេញបានសរុបចំនួន ២៦,៩០ប៊ីលានរៀល នៅក្នុងរយៈពេល

៨ខែឆ្នាំ២០២១ មានកំណើនយ៉ាងខ្លាំង ប្រហែលជា ៩០,៥% បើធៀបនឹងរយៈពេលដូចគ្នា ឆ្នាំមុន៕

*ដោយៈ មិត្ត ចន្ទី*

| បរិយាយ (គិតជាប៊ីលានរៀល) | ៨ខែឆ្នាំ២០២០ | ៨ខែឆ្នាំ២០២១ | កំណើន |
|---|---|---|---|
| **ចំណូលពន្ធលើពាណិជ្ជកម្មក្រៅប្រទេស** | **1,562.44** | **1,341.67** | **-14.1%** |
| ពន្ធ និងអាករលើការនាំចូល | 1,548.32 | 1,314.77 | -15.1% |
| ពន្ធ និងអាករលើការនាំចេញ | 14.12 | 26.90 | 90.5% |

*ប្រភព៖តារាងប្រតិបត្តការហិរញ្ញវត្ថុសម្រាប់ខែធ្នូ ឆ្នាំ២០២០ និងប្រចាំខែសីហាឆ្នាំ២០២១នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ*

## តារាងទី២ ៖ ពាណិជ្ជកម្មរវាងកម្ពុជា និងសហរដ្ឋអាមេរិក លើមុខទំនិញនៅក្នុងខែកញ្ញា ឆ្នាំ២០២១

យោងទៅតាមទិន្នន័យរបស់ការិយាល័យជំរឿនសហរដ្ឋអាមេរិកបង្ហាញថា៖ នៅក្នុងខែកញ្ញា ឆ្នាំ២០២១ ទំហំពាណិជ្ជកម្មរវាងប្រទេសកម្ពុជា និងសហរដ្ឋអាមេរិក មានទំហំទឹកប្រាក់សរុបចំនួន ៩៨០,២លានដុល្លារ មានកំណើនប្រមាណជា ១,៦% បើធៀបនឹងខែសីហា ឆ្នាំ២០២១។

ជាក់ស្តែង ការនាំចេញទំនិញរបស់កម្ពុជាទៅសហរដ្ឋអាមេរិក មានទំហំទឹកប្រាក់សរុប ៩៥៥,៤លានដុល្លារ នៅក្នុងខែកញ្ញា ឆ្នាំ២០២១ មានកំណើនប្រមាណជា ៣,៦% បើធៀបនឹងខែសីហា ឆ្នាំ២០២១។ ការនាំចេញនេះ ភាគច្រើនជាប្រភេទទំនិញរួមមាន៖ ចង្កៀងនិងគ្រឿងបំភ្លឺអគ្គិសនី កាបូបយួរ កាបូបលុយ សំលៀកបំពាក់ និងផលិតផលផ្សេងៗទៀត។

ក៏ប៉ុន្តែ ការនាំចូលទំនិញរបស់សហរដ្ឋអាមេរិកមកកម្ពុជា មានទំហំទឹកប្រាក់សរុប ២៤,៨លានដុល្លារនៅក្នុងខែកញ្ញា ឆ្នាំ២០២១ បានធ្លាក់ចុះប្រមាណជា ៤២,៣% បើធៀបនឹងខែសីហា។ ការនាំចូលទំនិញសំខាន់ៗទាំងនេះរួមមាន៖ រថយន្តធ្វើដំណើរ គ្រឿងបន្លាស់រថយន្ត កាកម្សៅ ស្ករស និងផលិតផលឯទៀត។*ដោយ មិត្ត ចន្ទី*

ប្រភព៖ការិយាល័យជំរឿនសហរដ្ឋអាមេរិក និងទិន្នន័យណិជ្ជកម្ម

| បរិយាយ | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា |
|---|---|---|---|---|---|---|---|---|---|
| **ទំហំពាណិជ្ជកម្ម** | **614.5** | **572.7** | **782.1** | **685.7** | **650.3** | **534.9** | **693.9** | **965.1** | **980.2** |
| កំណើន % | | -6.8% | 36.6% | -12.3% | -5.2% | -17.8% | 29.7% | 39.1% | 1.6% |
| នាំចូល | 33.9 | 33.3 | 39.1 | 29.4 | 38.1 | 28.8 | 33.2 | 43.0 | 24.8 |
| កំណើន % | | -1.8% | 17.4% | -24.8% | 29.6% | -24.4% | 15.3% | 29.5% | -42.3% |
| នាំចេញ | 580.6 | 539.4 | 743.0 | 656.3 | 612.2 | 506.1 | 660.7 | 922.1 | 955.4 |
| កំណើន % | | -7.1% | 37.7% | -11.7% | -6.7% | -17.3% | 30.5% | 39.6% | 3.6% |

សហរដ្ឋអាមេរិក (គិតជាលានដុល្លារ)

# ព័ត៌មាន និងទិន្នន័យរបស់បណ្តាប្រទេសនៅក្នុងអាស៊ាន និងដៃគូពាណិជ្ជកម្មដទៃទៀត

## កំណើនពាណិជ្ជកម្មបរទេសវៀតណាម កើន ១៨,៥% នៅខែវិច្ឆិកា




*ប្រភព៖ VietnamPlus*

ទំហំពាណិជ្ជកម្មបរទេសសរុបវៀតណាមក្នុងខែវិច្ឆិកា មានចំនួន ៥៩,៧ប៊ីលានដុល្លារ កើន ១៩,៧% ធៀបនឹងខែវិច្ឆិកា ឆ្នាំ២០២០ និងមានកំណើន ៨,៥% ធៀបនឹងទំហំពាណិជ្ជកម្មសរុបខែតុលា ដែលក្នុងនោះ ការនាំចេញសរុប មានទំហំ ២៩,៩ប៊ីលានដុល្លារ និងការនាំចូលសរុប មានទំហំ ២៩,៨ប៊ីលានដុល្លារ បើយោងតាមការិយាល័យស្ថិតិទូទៅ។

ចំណែកឯ ពាណិជ្ជកម្មបរទេសសរុប ពីខែមករា ដល់ខែវិច្ឆិកា មានទំហំលើសពី ៥៩៩,១ប៊ីលានដុល្លារ ដែល

មានកំណើន ២២,៣% ធៀបនឹងរយៈពេលដូចគ្នា ឆ្នាំកន្លងទៅ។

គួរបញ្ជាក់ថា សម្រាប់ការនាំចេញ សហរដ្ឋអាមេរិក នៅតែជាអ្នកទិញធំបំផុតរបស់វៀតណាម(៨៤,៨ប៊ីលានដុល្លារ) និងបន្ទាប់មកគឺ ប្រទេសចិន(៥០,៥ប៊ីលានដុល្លារ) សហភាពអឺរ៉ុប(៣៥,៧ប៊ីលានដុល្លារ) អាស៊ាន(២៥,៩ប៊ីលានដុល្លារ) កូរ៉េខាងត្បូង(២០ប៊ីលានដុល្លារ) និងជប៉ុន(១៨ប៊ីលានដុល្លារ)។ ដោយឡែក ការនាំចូលវិញ ប្រទេសចិន ជាអ្នកផ្គត់ផ្គង់ធំបំផុតរបស់វៀតណាម(៩៨,៥ប៊ីលានដុល្លារ) និងបន្ទាប់មក កូរ៉េខាងត្បូង(៥០,៣ប៊ីលានដុល្លារ) អាស៊ាន(៣៧ប៊ីលានដុល្លារ) ជប៉ុន(២០,៣ប៊ីលានដុល្លារ) សហ-ភាពអឺរ៉ុប(១៥,៥ប៊ីលានដុល្លារ) និងសហរដ្ឋអាមេរិក(១៤,២ប៊ីលានដុល្លារ)។

ជារួម អតិរេកពាណិជ្ជកម្មវៀតណាមសរុប សម្រាប់ ១១ខែ ឆ្នាំ២០២១ មានទំហំត្រឹមតែ ២២៥លានដុល្លារ បើធៀបនឹង ២០,១៩ប៊ីលាន សម្រាប់រយៈពេលដូចគ្នានៅឆ្នាំ២០២០៕ *ដោយ **ជា សិរីរតន៍***

*ប្រភព៖ VietnamPlus ចេញផ្សាយ ថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០២១*

## ទំហំពាណិជ្ជកម្មកម្ពុជា និងឥណ្ឌូនេស៊ី សម្រេចបានជាង ៥១៣លានដុល្លារ ក្នុងរយៈពេល១០ខែឆ្នាំនេះ




ការដោះដូរពាណិជ្ជកម្មរវាងកម្ពុជា និងប្រទេសឥណ្ឌូនេស៊ី ក្នុងរយៈពេល១០ខែ ឆ្នាំ២០២១នេះ សម្រេចបានជាង ៥១៣លានដុល្លារ ធ្លាក់ចុះជាង១១%។ កម្ពុជាបាននាំចេញទំនិញផ្សេងៗ ដូចជា កៅស៊ូ និងផលិតផលធ្វើពីកៅស៊ូ ក្រដាស ក្រដាសកាតុង សម្លៀកបំពាក់ ស្បែកជើង ស្រោមជើង អាលុយមីញ៉ូម និងសម្ភារៈអគ្គិសនីជាដើម។ ចំណែកឥណ្ឌូនេស៊ីនាំចូលមកកម្ពុជាវិញនូវផលិតផលរួមមាន ៖ សម្ភារធ្វើពីថ្ម ម្នាងសិលា ស៊ីម៉ង់ត៍ ផលិតផលកុលភាជន៍ ស្បែកជើង ស្រោមជើង សំលៀកបំពាក់ ត្បូងគ្រឿងអលង្ការកាឡៃ ដែកអាលុយមីញ៉ូម គ្រឿងចក្រកសិកម្ម និងគ្រឿងសង្ហារឹមជាដើម។

នៅឆ្នាំ២០២០ ទំហំពាណិជ្ជកម្មរវាងប្រទេសទាំងពីរ មានចំនួនជិត៥៧៨លានដុល្លារ។ ក្នុងនោះកម្ពុជានាំចេញទៅឥណ្ឌូនេស៊ីជិត ២៩លានដុល្លារ ហើយនាំចូលជិត ៥៤៩លានដុល្លារ៕ *ដោយ ម៉ែន ខែមរៈ*

*ប្រភព៖freshnews ចេញផ្សាយថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២១។*

## បំណុលប្រជាជនថៃ កើនដល់៨៩,៣% នៃផ.ស.ស



*ប្រភព៖ AsiaNews ២០២១*

យោងតាមការស្ទង់មតិថ្មីៗដោយ Suan Dusit បង្ហាញថា ប្រជាជនថៃ ១ ក្នុងចំណោម ២នាក់ ជំពាក់បំណុលកាតឥណទាន(credit card debts) ឬបំណុលមានទ្រព្យបញ្ចាំ(mortgage) ហើយប្រជាជនថៃ ជាមធ្យមជំពាក់បំណុលកាតឥណទាន និងឥណទានបុគ្គល តម្លៃសរុប ១,២៤លានបាត(ឬ ៣៧ ០០០ដុល្លារ)។ បន្ថែមពីនេះ វិបត្តិជំងឺរាតត្បាត បានធ្វើឱ្យការទូទាត់សងបំណុលកាន់តែលំបាក។

ក្នុងចំណោមអ្នកឆ្លើយតបទាំងអស់ ប្រមាណជា ៤៦,៥២% បាននិយាយថា ពួកគេបានជំពាក់បំណុលក្រុមហ៊ុនកាតឥណទាន ស្របពេលដែល ៣៩,៨៥% ជំពាក់បំណុលមានទ្រព្យបញ្ចាំ។

ស្របពេលជាមួយគ្នានេះដែរ បំណុលប្រជាជនថៃ នៅក្នុងត្រីមាសទី២ ឆ្នាំនេះ បានកើនទៅដល់ ១៤,២៧ទ្រីលានបាត ដែលសមមូលនឹង ៨៩,៣%នៃផ.ស.ស បើយោងតាមក្រុមប្រឹក្សាអភិវឌ្ឍសង្គម និសេដ្ឋកិច្ចជាតិ។ ជាលទ្ធផល ប្រទេសថៃ បានជាប់ចំណាត់ទី៥ នៅក្នុងអាស៊ី និងទី១២ ក្នុងប្រទេសចំនួន ៧០ ដែលរងការប៉ះពាល់ដោយបំណុលខ្លាំងបំផុត។

ទន្ទឹមនេះ បំណុលប្រជាជន នឹងនៅតែបន្តកើនឡើង ដោយសារតែសេដ្ឋកិច្ចនៅមិនទាន់ស្តារបានទាំងស្រុង ក៏ដូចជាបញ្ហាទឹកជំនន់ និងបញ្ហារយៈពេលខ្លីមួយចំនួនទៀត ដូចជា អាកាសធាតុជាដើម។ គួរបញ្ជាក់ផងដែរថា ប្រជាជនថៃ បានកំពុងប្រឈមនឹងបញ្ហាខ្វះខាតសន្ទនីយភាព ដែលអាចឃើញតាមរយៈការកើនឡើងបំណុលក្រៅប្រព័ន្ធ (Informal Debt កើន ១,៥ដង ធៀបនឹងឆ្នាំ២០១៩)។ *ដោយ **ជា សិរីរតន៍***

*ប្រភព៖ <u>AsiaNews</u> ចេញផ្សាយ ថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០២១*

## សន្ទស្សន៍ថ្លៃទំនិញការនាំចូលរបស់សិង្ហបុរីក្នុងខែតុលា ឆ្នាំ២០២១

យោងតាមទិន្នន័យរបស់នាយកដ្ឋានស្ថិតិសិង្ហបុរីបានបង្ហាញថា៖សន្ទស្សន៍ថ្លៃទំនិញនៃការនាំចូលរបស់សិង្ហបុរីកើនឡើង ៣%នៅក្នុងខែតុលាឆ្នាំ២០២១ ធៀបនឹង ខែកញ្ញា និងកើនឡើង ២០% ក្នុខែតុលា ឆ្នាំ ២០២១ ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំកន្លងទៅ។ សន្ទស្សន៍ថ្លៃប្រេងកើនឡើង ១០,៨% និងសន្ទស្សន៍ទំនិញមិនមែនប្រេងថយចុះ ០,១%នៅក្នុងខែតុលា ឆ្នាំ ២០២១។

ការធ្លាក់ចុះនៃសន្ទស្សន៍ថ្លៃទំនិញមិនមែនប្រេងដោយសារការកាត់កងរឿងការកើនឡើងនៃសន្ទស្សន៍ថ្លៃទំនិញ ឧស្សាហកម្ម ១,២% សន្ទស្សន៍ផលិតផលគីមីកើនឡើង០,៩% (ការកើនឡើងនេះដោយសារថ្លៃដែក និងផលិតផលធ្វើពីដែកកើនឡើង)។ ក៏ប៉ុន្តែសន្ទស្សន៍ថ្លៃទំនិញ ភេសជ្ជៈ និងថ្នាំជក់បានធ្លាក់ចុះ -២,៥% និងសន្ទស្សន៍ថ្លៃគ្រឿងចក្រ និងឧបករណ៍ដឹកជញ្ជូនធ្លាក់ចុះ -០,២%។ *ដោយ មុំ ចិន្តា*

*ប្រភព៖ <u>statistic of Singapore ថ្ងៃទី២៩ វិច្ឆិកា ឆ្នាំ២០២១</u>*

### តារាងប្រៀបធៀបសន្ទស្សន៍ថ្លៃទំនិញ

| ប្រភេទនៃមុខទំនិញ | សន្ទស្សតម្លៃ(2018=100) | | | % ប្រែប្រួល | | |
|---|---|---|---|---|---|---|
| | | | | កញ្ញា-២១ | តុលា-២១ | តុលា-២១ |
| | សីហា-២១ | កញ្ញា-២១ | តុលា-២១ | សីហា-២១ | កញ្ញា-២១ | តុលា-២០ |
| ***សរុប*** | ***104*** | ***105.9*** | ***109.1*** | ***1.8%*** | ***3.0%*** | ***20.0%*** |
| មិនមែនប្រេង | 103.3 | 103.3 | 103.4 | 0.0% | 0.1% | 3.0% |
| ម្ហូប និងសត្វរស់ | 106.1 | 105.8 | 106.6 | -0.3% | 0.8% | 5.1% |
| ភេសជ្ជៈ និងថ្នាំជក់ | 107.4 | 107 | 104.3 | -0.4% | -2.5% | 9.7% |
| វត្ថុធាតុដើម(មិនរាប់បញ្ចូលប្រេងឥន្ធនៈ) | 107 | 106.4 | 106.4 | -0.6% | 0.0% | 4.5% |
| សត្វ បន្លែ ប្រេង ខ្លាញ់ | 154.3 | 155.6 | 162.8 | 0.8% | 4.6% | 50.2% |
| សារធាតុគីមី និងផលិតផលគីមី | 105.5 | 105.5 | 106.5 | 0.0% | 0.9% | 9.4% |
| ទំនិញឧស្សាហកម្ម | 112.6 | 113.6 | 115 | 0.9% | 1.2% | 15.6% |
| ម៉ាស៊ីន គ្រឿងចក្រ និងឧបករណ៍ដឹកជញ្ជូន | 100.6 | 100.5 | 100.3 | -0.1% | -0.2% | 0.2% |
| ផលិតផលផ្សេងៗ | 107.2 | 106.9 | 107 | -0.3% | 0.1% | 1.1% |
| ប្រេង | 106.1 | 113.4 | 125.6 | 7% | 10.8% | 95.9% |
| តេសសិលា និងវត្ថុធាតុដែលពាក់ព័ន្ធ | 107 | 114.8 | 127.2 | 7.3% | 10.8% | 96.7% |
| ឧស្ម័ន | 92.2 | 92.4 | 101.6 | 0.2% | 10.0% | 80.4% |

*ប្រភព៖ <u>Statistics Singapore</u>*

## ថ្នាក់ដឹកនាំធនាគារកណ្ដាលវៀតណាម លើកសរសើរពីវឌ្ឍនភាពនៃវិស័យធនាគារនៅកម្ពុជា



*ដោយ ខេមបូណ្ឌមីស(លោកជំទាវ ទេសាភិបាលធនាគាររដ្ឋវៀតណាម)*

នាកិច្ចប្រជុំទ្វេភាគីរវាងធនាគារជាតិនៃកម្ពុជា និងធនាគាររដ្ឋវៀតណាម បានពិភាក្សាផ្លាស់ប្ដូរយោបល់លើវឌ្ឍនភាពនៃស្ថានភាពម៉ាក្រូសេដ្ឋកិច្ចកម្ពុជា, ការអភិវឌ្ឍវិស័យធនាគារ, វិធានការឆ្លើយតបរបស់ធនាគារកណ្ដាលចំពោះឥទ្ធិពលអវិជ្ជមាននៃជំងឺកូវីដ-១៩, ការជំរុញការទូទាត់ដោយមិនប្រើក្រដាសប្រាក់ និងការពិនិត្យមើលអំពីវឌ្ឍនភាពនៃការកំណត់ទិសដៅនៃកិច្ចសហប្រតិបត្តិការទ្វេភាគីជាដើម។

ទេសាភិបាលធនាគាររដ្ឋវៀតណាម បានលើកសរសើរពីការគ្រប់គ្រង និងវឌ្ឍនភាពនៃវិស័យធនាគារនៅកម្ពុជា ថានៅតែអាចដំណើរការដោយរលូន បើទោះបីស្ថិតក្នុងបរិបទកូវីដ-១៩ក៏ដោយ ហើយសម្រេចបានសមិទ្ធផលល្អក្នុងការរក្សាបានវឌ្ឍនភាព និងស្ថិរភាពប្រព័ន្ធធនាគារ និងរក្សាបានស្ថិរភាពអត្រាប្ដូរប្រាក់ និងកម្រិតអតិផរណាទាប។ ហើយក៏បានអបអរសាទរ ចំពោះការដាក់ឱ្យប្រើប្រាស់ប្រព័ន្ធទូទាត់ទំនើប ជាពិសេស ប្រព័ន្ធបាគង ដែលជួយដោះស្រាយបញ្ហាទូទាត់ឆ្លងគ្រឹះស្ថាន និងការតភ្ជាប់ជាមួយប្រព័ន្ធទូទាត់ទាំងក្នុងស្រុកនិងតំបន់។

អគ្គទេសាភិបាលធនាគារកម្ពុជា ក៏បានថ្លែងអំណរគុណចំពោះធនាគាររដ្ឋវៀតណាម ដែលបានផ្ដល់កិច្ចសហប្រតិបត្តិការល្អប្រសើរ ក្រោមអនុស្សរណៈយោគយល់រវាងធនាគារកណ្ដាលទាំងពីរទៅលើកិច្ចសហប្រតិបត្តិការទូទៅ, លើការត្រួតពិនិត្យធនាគារ និងលើការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ក៏ដូចជាការគាំទ្រផ្នែកធនធានមនុស្សនៅកម្ពុជា ផងដែរ។

កិច្ចប្រជុំខាងលើភាគីទាំងពីរបានពិភាក្សាអំពីវឌ្ឍនភាពនៃកិច្ចសហប្រតិបត្តិការទ្វេភាគី រវាងធនាគារកណ្ដាលទាំងពីរ និងកិច្ចសហប្រតិបត្តិការល្អរវាងវិស័យធនាគារ ដែលបានរួមចំណែកគាំទ្រកំណើនពាណិជ្ជកម្ម ការវិនិយោគ និងទេសចរណ៍ ក្នុងប្រទេសទាំងពីរផងដែរ៕

*ដោយ ម៉ែន ខែមរៈ*

*ប្រភព៖ខេមបូណ្ឌមីស ចេញផ្សាយថ្ងៃទី២៦ខែវិច្ឆិកា ឆ្នាំ២០២១។*

## EUនឹងបន្តផ្ដល់ជំនួយគាំទ្រកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៅកម្ពុជា



នៅក្នុងជំនួបពិភាក្សាការងារជាមួយឯកអគ្គរដ្ឋទូតនៃសហភាពអឺរ៉ុបប្រចាំកម្ពុជា រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានថ្លែងអំណរគុណចំពោះសហភាពអឺរ៉ុប ដែលជួយគាំទ្រដល់កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈចាប់តាំងពីឆ្នាំ២០០៥ រហូតមកដល់បច្ចុប្បន្ន ក៏ដូចជាការគាំទ្រចំពោះកម្មវិធីកែទម្រង់ផ្សេងៗទៀតរបស់រាជរដ្ឋាភិបាលកម្ពុជា។ ដើម្បីត្រៀមខ្លួនដោះស្រាយហានិភ័យចម្បងៗជាយថាហេតុ រាជរដ្ឋាភិបាលកម្ពុជា កំពុងជំរុញដាក់ឱ្យអនុវត្តនូវ «ក្របខ័ណ្ឌយុទ្ធសាស្ត្រ និងកម្មវិធីស្ដារ និងជំរុញកំណើនសេដ្ឋកិច្ចកម្ពុជា

ក្នុងការរស់នៅជាមួយកូវីដ-១៩ តាមគន្លងប្រក្រតីភាពថ្មី ២០២១-២០២៣» ដែលឈរលើសសរស្តម្ភបី (ហៅថា 3Rs) គឺ៖ សសរស្តម្ភទី១ «ការស្តារ (Recovery)»គឺ ស្តារឡើងវិញនូវវិស័យដែលទទួលរងនូវឥទ្ធិពលអវិជ្ជមានខ្លាំងរបស់ជំងឺកូវីដ១៩,សសរស្តម្ភទី២«ការកែទម្រង់ (Reforms)»គឺកែទម្រង់គ្រប់ផ្នែកគ្រប់វិស័យសម្រាប់ទាក់ទាញការវិនិយោគ និងសសរស្តម្ភទី ៣ «ការកសាងភាពធន់ (Resiliency)» ដើម្បីធានាបាននូវចីរភាពសេដ្ឋកិច្ច និងភាពប្រកួតប្រជែង ជាដើម។

ឯកអគ្គរដ្ឋទូត ក៏បានថ្លែងកោតសរសើរ ចំពោះកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ រហូតដល់សម្រេចបាននូវសមិទ្ធផលជាច្រើន និងចាត់ទុកថា កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈគឺជា «ឆ្អឹងខ្នង» ដើម្បីគាំទ្រការកែទម្រង់វិស័យផ្សេងទៀត សំដៅអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គម ប្រកបដោយជោគជ័យ ចីរភាព និងបរិយាប័ន្ន។ សម្រាប់ជំហានបន្ទាប់សហភាពអឺរ៉ុប នឹងបន្តគាំទ្រដល់កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

ដោយឯកអគ្គរដ្ឋទូត បានបញ្ជាក់ថា ក្របខ័ណ្ឌលទ្ធផលនៃកិច្ចព្រមព្រៀងហិរញ្ញប្បទានឥតសំណងថ្មី រវាងរាជរដ្ឋាភិបាលកម្ពុជា និងសហភាពអឺរ៉ុប នឹងផ្តោតលើសមាសធាតុគន្លឹះនៃការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរួមមាន ៖ ការពង្រឹងការកៀរគរចំណូលក្នុងស្រុក, ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន សម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, ថវិកាផ្សារភ្ជាប់ទៅនឹងគោលនយោបាយ, ការគ្រប់គ្រងវិនិយោគសាធារណៈ ផ្សារភ្ជាប់ជាមួយការប្រែប្រួលអាកាសធាតុ និងការពង្រឹងប្រសិទ្ធភាពលទ្ធកម្មសាធារណៈ ។

ជាមួយគ្នានេះ, ដើម្បីឱ្យការរៀបចំក្របខ័ណ្ឌលទ្ធផលសម្រាប់កិច្ចព្រមព្រៀងហិរញ្ញប្បទានឥតសំណងថ្មីនេះ បានឆាប់រហ័ស រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានណែនាំដល់ក្រុមការងារបច្ចេកទេសទាំងពីរភាគី ខាងរាជរដ្ឋាភិបាល និងសហភាពអឺរ៉ុប ចាប់ផ្តើមធ្វើការរួមគ្នាឱ្យបានឆាប់៕ *ដោយ ម៉ែន ខែមរៈ*

*ប្រភព ៖ freshnews ចេញផ្សាយថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ២០២១។*

## ឡាវសង្ឃឹមថា សេដ្ឋកិច្ចនឹងស្ទុះឡើងចេញពីផ្លូវដែកថ្មី



*ដោយ ស្មើកម្ពុជា*

ផ្លូវដែក ប្រវែង៤១៤គីឡូម៉ែត្រ បានចំណាយពេលស្ថាបនា៥ឆ្នាំ ក្រោមគំនិតផ្តួចផ្តើមខ្សែក្រវាត់ និងផ្លូវដោយមូលនិធិរបស់ចិន តម្លៃ៦ពាន់លានដុល្លារ នឹងបើកអោយដំណើរការនៅដើមខែធ្នូ។ ពីមុនប្រទេសឡាវមានផ្លូវរថភ្លើងតែ៤គីឡូម៉ែត្រ។ ប៉ុន្តែពេលនេះ រថភ្លើងក្បាលគ្រាប់ពណ៌ក្រហមខៀវសដ៏រលោង នឹងបង្ហាញខ្លួនលើផ្លូវថ្មី ក្នុងល្បឿន១៦០គីឡូម៉ែត្រក្នុង១ម៉ោង ឆ្លងកាត់ផ្លូវរូងក្រោមដី៧៥ ស្ពាន១៦៧ និងឈប់នៅស្ថានីយអ្នកដំណើរចំនួន១០។ ផ្លូវនេះ នាំក្តីសង្ឃឹមអំពីការជំរុញសេដ្ឋកិច្ចនៅក្នុងប្រទេសក្រីក្រមិនមានដាប់សមុទ្រមួយនេះ។

លោកអានូផុន ផុមហាកសា ម្ចាស់កសិដ្ឋានដំណាំផ្លែស្ត្របឺរី កំពុងសង្ឃឹមលើផ្លូវដែកថ្មីនេះ អាចជួយអាជីវកម្មរបស់គាត់វិលមកស្ថានភាពដើមវិញ។ តាមធម្មតា គាត់ផលិតបានផ្លែស្ត្របឺរី២តោនក្នុងមួយឆ្នាំ ហើយដឹកជញ្ជូនស្ត្របឺរីទៅកាន់ទីក្រុងវៀងចន្ទន៍ តាមផ្លូវផ្ទាល់បាន

ប្រើពេល៣ម៉ោង។ គាត់សង្ឃឹមថា ផ្លូវថ្មីនេះនឹងកាត់បន្ថយពេលដឹកជញ្ជូនបានច្រើន។ មិនត្រឹមតែប៉ុណ្ណោះ ផ្លូវនេះ អាចធ្វើឱ្យទេសចរធ្វើដំណើរមកបោះជំរំមើលផ្កាយ និងទិញផ្លែស្ត្របឺរី នៅកសិដ្ឋានរបស់លោកបាន។ ហើយនាពេលអនាគត នឹងមានទេសចរច្រើន មកកាន់កសិដ្ឋានរបស់លោក។

ផ្លូវដែកនេះនឹងភ្ជាប់រដ្ឋធានីវៀងចន្ទន៍របស់ឡាវ ទៅកាន់ទីក្រុងគុនមិញរបស់ចិន ហើយផែនការមេផ្លូវរថភ្លើងល្បឿនលឿននេះនឹងពង្រីកទៅកាន់ថៃ ម៉ាឡេស៊ីនិងសិង្ហបុរី។ យោងតាមរបាយការណ៍របស់ធនាគារពិភពលោក ផ្លូវដែកថ្មីនេះ នឹងជួយជំរុញវិស័យទេសចរណ៍ ការដឹកជញ្ជូន និងកសិកម្ម៕ *ដោយ ម៉ែន ខែមរៈ*
*ប្រភព ៖ រស្មីកម្ពុជា ចេញផ្សាយថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០២១។*

## តើការនាំចេញពីកម្ពុជាទៅជប៉ុនសម្រេចបានលទ្ធផលអ្វីខ្លះក្នុងវិបត្តិកូវីដ១៩ នៅក្នុង១០ខែឆ្នាំនេះ?



*ដោយ ខេមបូណ្ណមីស*

ការនាំចេញទំនិញរបស់កម្ពុជាទៅកាន់ទីផ្សារជប៉ុននៅតែធ្វើបានល្អ នៅរយៈពេលជិត១ឆ្នាំកន្លងមកនេះ។ នៅ១០ខែក្នុងឆ្នាំ២០២១ កម្ពុជាសម្រេចបានទំហំនាំចេញទំនិញទៅជប៉ុនជាង៩២០លានដុល្លារ កើនឡើងជាង ៥% បើធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុន ដែលមានទឹកប្រាក់ជាង ៨៧៤លានដុល្លារ។ ទំហំពាណិជ្ជកម្មទ្វេភាគីកម្ពុជា-ជប៉ុនកើនដល់ជាង១ពាន់៤រយលានដុល្លារនៅ១០ខែឆ្នាំនេះ បន្ទាប់ពីជប៉ុនសម្រេចបានទំហំនាំចូលមកកម្ពុជាជិត៥រយលានដុល្លារអាមេរិក ធ្លាក់ចុះជាង៥% បើធៀបនឹងខែកាលពីឆ្នាំ២០២០ ដែលមានជាង៥២៣លានដុល្លារ។ ជុំវិញភាពខុសគ្នារវាងតួលេខនាំចេញនាំចូលរវាងប្រទេសទាំងពីរ គឺដោយសារកំណើនត្រូវការកសិផលពីកម្ពុជាទៅជប៉ុន រីឯតម្រូវការផលិតផលជប៉ុន(រថយន្ត និងគ្រឿងអេឡិចត្រូនិក)នៅកម្ពុជាមានការថយចុះ បន្ទាប់ពីប្រជាពលរដ្ឋកម្ពុជាបានបាត់បង់ប្រាក់ចំណូលក្នុងអំឡុងនៃវិបត្តិកូវីដ-១៩។

អ្នកជំនាញ បានកត់សម្គាល់ឃើញថា ក្នុងអំឡុងនៃវិបត្តិកូវីដ-១៩ មានវិនិយោគិនជាតិ និងអន្តរជាតិជាច្រើនបានងាកមកវិនិយោគលើការផលិត និងកែច្នៃផលិតផលកសិកម្ម ដែលកត្តានេះបានជំរុញឱ្យការនាំចេញកសិផល ផលិតផល និងកសិ-ឧស្សាហកម្មរបស់កម្ពុជារក្សាបាននូវកំណើន។

ផលិតផលដែលកម្ពុជាបាននាំចេញទៅជប៉ុន រួមមានផលិតផលវាយណ្ឌភាព ស្បែកជើង ស្បៀងអាហារ និងគ្រឿងបង្គុំអេឡិចត្រូនិកជាដើម។ ចំណែកកម្ពុជានាំចូលពីជប៉ុនរួមមាន ស្បៀងអាហារ ទំនិញឧស្សាហកម្ម ផលិតផលពេទ្យ គ្រឿងម៉ាស៊ីន រថយន្ត និងគ្រឿងអេឡិចត្រូនិក។

ទំហំពាណិជ្ជកម្មទ្វេភាគីកម្ពុជា-ជប៉ុន កាលពីឆ្នាំ២០២០ សម្រេចបានជិត១ពាន់៧រយលានដុល្លារ ធ្លាក់ចុះ១៦% បើប្រៀបធៀបនឹងឆ្នាំ២០១៩ ដែលមានជាង២ពាន់លានដុល្លារអាមេរិក(កម្ពុជានាំចេញជាង១ពាន់លានដុល្លារ នាំចូលពីជប៉ុនមានទំហំជាង៦៣៧លានដុល្លារ)៕ *ដោយ ម៉ែន ខែមរៈ*
*ប្រភព៖ខេមបូណ្ណមីសចេញផ្សាយថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០២១។*

## ឯកអគ្គរដ្ឋទូតឆែកសន្យាជំរុញវិនិយោគិន មកបណ្តាក់ទុននៅកម្ពុជា



*ដោយ ams*

ប្រទេសកម្ពុជា និងឆែក បានភ្ជាប់ទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការជាមួយគ្នា អស់រយៈពេលជាយូរមកហើយ ហើយទទួលបានផ្លែផ្កាដែលកើតចេញពីកិច្ចសហប្រតិបត្តិការដ៏ល្អនេះ ជារៀងរហូតមក។ នៅក្នុងដំណាក់កាលជាបន្តបន្ទាប់ ឆែកបានរួមចំណែកអភិវឌ្ឍកម្ពុជាយ៉ាងច្រើន គឺតាំងពីអតីតឆេកូស្លូវ៉ាគី រហូតដល់បច្ចុប្បន្ន។ ប្រទេសឆែក បានផ្តល់ជំនួយទ្វេភាគីមកកម្ពុជាជាច្រើននៅក្នុងវិស័យសុខាភិបាល និងអប់រំ។ កាលពីពេលថ្មីនេះជំនួយឧបករណ៍បរិក្ខារពេទ្យជាច្រើនបានផ្តល់ជូនមន្ទីរពេទ្យខេត្តតាកែវ ហើយឆែកនៅបន្តផ្តល់ជំនួយមនុស្សធម៌មកកម្ពុជាបន្តបន្ទាប់ទៀត ពិសេសអាហារូបករណ៍ដល់សិស្ស និស្សិត និងមន្ត្រីរាជការកម្ពុជាបានទៅសិក្សានៅសាធារណរដ្ឋឆែក។

បេសកកម្មការទូតថ្មីរបស់ប្រទេសឆែក នៅកម្ពុជា គឺមានសារៈសំខាន់ក្នុងការបន្តលើកកម្ពស់ទំនាក់ទំនងចំណងមិត្តភាព និងកិច្ចសហប្រតិបត្តិការរវាងប្រទេសទាំងពីរ ដែលមានស្រាប់ឱ្យកាន់តែល្អប្រសើរមួយកម្រិតថែមទៀត។ ឆ្លើយតបសំណូមពររបស់សម្តេចអគ្គមហាពញាចក្រី ហេង សំរិន ប្រធានរដ្ឋសភា ចំពោះប្រទេសឆែក បន្តជំរុញកិច្ចសហប្រតិបត្តិការលើវិស័យពាណិជ្ជកម្ម វិនិយោគ និងទេសចរណ៍ ឱ្យកាន់តែល្អប្រសើរថែមទៀត ក្រោយជំងឺរាតត្បាតកូវីដ ១៩ បានធូរស្បើយ។ ឯកឧត្តមឯកអគ្គរដ្ឋទូតថ្មី នៃសាធារណរដ្ឋឆែក បានជម្រាបជូនសម្តេចថា ក្រុមហ៊ុនរបស់ឆែកបាននិងកំពុងវិនិយោគនៅក្នុងប្រទេសថៃ និងប្រទេសវៀតណាម ដូច្នេះឯកឧត្តមនឹងសិក្សាដើម្បីជំរុញកិច្ចសហប្រតិបត្តិការពាណិជ្ជកម្មរវាងប្រទេសទាំងពីរឱ្យកាន់តែមានទំហំធំឡើង។

រដ្ឋសភាកម្ពុជា សូមគាំទ្រចំពោះបេសកកម្មការទូត និងត្រៀមធ្វើកិច្ចសហប្រតិបត្តិការពេញលេញ ដើម្បីឱ្យបេសកកម្មការទូតនេះ ទទួលបានជោគជ័យ៕ *ដោយ ម៉ែន ខែមរៈ*

*ប្រភព ៖ ams ចេញផ្សាយថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០២១។*

## ក្រោយ FTA កម្ពុជា-ចិន ចូលជាធរមាន តើកម្ពុជារំពឹងនាំចេញអង្ករបានប៉ុន្មានម៉ឺនតោនទៅទីផ្សារចិន?




*ដោយ ខេមបូឌាមីស*

បើតាមការបញ្ជាក់របស់ប្រមុខដឹកនាំរាជរដ្ឋាភិបាលកម្ពុជា និងស្ថានទូតចិនប្រចាំនៅកម្ពុជា កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីកម្ពុជា-ចិន នឹងចូលជាធរមាននៅថ្ងៃទី ១ មករា ឆ្នាំ២០២២។ ក្រោមកិច្ចព្រមព្រៀងនេះកម្ពុជាអាចនាំចេញទំនិញជាង៣០០មុខទៅកាន់ទីផ្សារចិនដោយរួចពន្ធ។ ថ្នាក់ដឹកនាំក្រសួងពាណិជ្ជកម្មរំពឹងថាការនាំចេញពីកម្ពុជាទៅចិន នឹងមានកំណើន២៥% បន្ថែមទៀតក្រោមកិច្ចព្រមព្រៀងនេះ។

សហព័ន្ធស្រូវអង្ករកម្ពុជា មានជំនឿចិត្តខ្ពស់ ចំពោះឥទ្ធិពលនៃកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីកម្ពុជា-ចិន ក្នុងការជួយជំរុញកំណើននៃការនាំចេញអង្ករកម្ពុជាទៅកាន់ទីផ្សារក្រៅប្រទេសពិសេសទីផ្សារចិន បន្ទាប់ពីកិច្ចព្រមព្រៀងនេះ នឹងចូលជាធរមាន ហើយកម្ពុជានឹងអាចទទួលបានកូតានាំចេញអង្ករបន្ថែមទៀត។

បច្ចុប្បន្ន ស្ថានភាពការនាំចេញអង្ករពីកម្ពុជាទៅទីផ្សារអន្តរជាតិហាក់មានស្ថានភាពល្អប្រសើរឡើងវិញបន្តិច ហើយ ដែលរំពឹងថានឹងមានកំណើននាំចេញខ្ពស់នៅចុងឆ្នាំ២០២១នេះ។ ទោះយ៉ាងណា ថ្លៃដឹកជញ្ជូននៅតែមានតម្លៃខ្ពស់ដដែល ទោះបីបញ្ហាកង្វះទូកុងតឺន័រហាក់មានភាពធូរស្បើយឡើងវិញបន្តិចក្តី។ កន្លងមកកម្ពុជាបាននាំចេញអង្ករទៅកាន់ទីផ្សារនេះ បានចន្លោះពី២៧ទៅ៣០ម៉ឺនតោនតែប៉ុណ្ណោះក្នុង១ឆ្នាំ។ ប្រសិនបើគ្មានការផ្ទុះការឆ្លងជំងឺកូវីដ-១៩សារជាថ្មី នៅតាមប្រទេសបញ្ជាទិញ នោះនឹងអាចនាំចេញអង្ករទៅកាន់ទីផ្សារអន្តរជាតិបានក្នុងរង្វង់១០ម៉ឺនតោននៅអំឡុងខែធ្នូខាងមុខនេះ ដែលវានឹងជួយជំរុញកំណើននៃការនាំចេញអង្កររបស់កម្ពុជានៅឆ្នាំ២០២១ អាចប្រហាក់ប្រហែលនឹងបរិមាណនៅឆ្នាំ២០២០។

យោងតាមរបាយការណ៍របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទបានបញ្ជាក់ថា នៅរយៈពេល១០ខែក្នុងឆ្នាំ២០២១ កម្ពុជាបាននាំចេញអង្ករទៅកាន់ទីផ្សារអន្តរជាតិសម្រេចបានជាង៤៦ម៉ឺនតោនថយចុះ ៣៣% បើធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុន។ ចំណែកការនាំចេញស្រូវសម្រេចបានជាង២លានតោន គិតជាប្រាក់មានជាង៤៦៥លានដុល្លារ កើនឡើង ៨៦% បើធៀបនឹង១០ខែកាលពីឆ្នាំ២០២០។ *ដោយ ម៉ែន ខែមរៈ*

*ប្រភព៖ខេមបូឌាមីសចេញផ្សាយថ្ងៃទី២៩ខែវិច្ឆិកា ឆ្នាំ២០២១។*

## វៀតណាម នាំមុខថៃ និងម៉ាឡេស៊ី ជាប្រទេសទិញលក់ទំនិញតាមប្រព័ន្ធអេឡិចត្រូនិកច្រើនជាងគេ



*ដោយ ខេមបូឌាមីស(ការទិញតាមប្រព័ន្ធអនឡាញនៅវៀតណាម)*

ការប្រើប្រាស់ឌីជីថលនៅប្រទេសវៀតណាម បានក្លាយជាទម្លាប់ថ្មីមួយនៃការទិញ-លក់ទំនិញតាមអនឡាញ ហើយបានធ្វើឱ្យប្រទេសនេះក្លាយជាជើងឯកថ្មី នៅក្នុងទីផ្សារពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក E-commerce នៅតំបន់អាស៊ីអាគ្នេយ៍។ នៅក្នុងត្រីមាសទី៣នៅឆ្នាំ២០២១ ការទិញ-លក់ទំនិញតាមប្រព័ន្ធអេឡិចត្រូនិក E-commerce នៅប្រទេសវៀតណាមមានលើសប្រទេសថៃដល់ទៅទ្វេដង និងលើសប្រទេសម៉ាឡេស៊ីដល់ទៅ៣ដង ដែលបញ្ជាក់ឱ្យឃើញពីតម្រូវការទិញទំនិញតាមអនឡាញនៅវៀតណាម មានកំណើនខ្ពស់គួរឱ្យកត់សម្គាល់ នៅអំឡុងពេលនៃវិបត្តិជំងឺរាតត្បាតកូវីដ១៩នេះ។

តាមរបាយការណ៍របស់ក្រុមហ៊ុន Google, Temasek និង Bain & Co បានឱ្យដឹងទៀតថា ប្រទេសវៀតណាមនឹងនាំមុខប្រទេសថៃនៅត្រឹមឆ្នាំ២០២៥ ក្លាយជាប្រទេសមានសេដ្ឋកិច្ចពាណិជ្ជកម្មតាមបណ្តាញអ៊ីនធើណែតធំជាងគេបំផុតទី២ នៅក្នុងតំបន់អាស៊ីអាគ្នេយ៍ ដោយមានទំហំទីផ្សារដល់ទៅ ៥៧ពាន់លានដុល្លារអាមេរិក តាមពីក្រោយប្រទេសឥណ្ឌូនេស៊ី ដែលមានទំហំទីផ្សារ ១៤៦ពាន់លានដុល្លារអាមេរិក។

របាយការណ៍ក្រុមហ៊ុនiPrice បានរកឃើញថា អ្នកប្រើប្រាស់នៅក្នុងប្រទេសវៀតណាមនិយមប្រើបណ្តាញ

សង្គមធ្វើជាកន្លែងទិញលក់ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ជាងអ្នកប្រើប្រាស់នៅប្រទេសថៃ ប៉ុន្តែនៅតិចជាងម៉ាឡេស៊ី។ កត្តានេះ បានបង្ហាញឱ្យឃើញថាហ្វេសប៊ុកគឺមានសារៈសំខាន់ណាស់ ក្នុងការផ្សព្វផ្សាយម៉ាក្សផលិតផលនៅវៀតណាម។ *ដោយ ម៉ែន ខែមរៈ ប្រភព៖ខេមបូណ្ឌមីសចេញផ្សាយថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០២១។*

## សេដ្ឋកិច្ចសកល

### អង្គការសហប្រជាជាតិបាននិយាយថា ទស្សនៈវិស័យកំណើនពាណិជ្ជកម្មពិភពលោកឆ្នាំ២០២២ មានភាពមិនច្បាស់លាស់



*ផ្លាកសញ្ញាUNមុនពេលប្រមុខរដ្ឋចាប់ផ្តើមថ្លែងសន្ទរកថានៅក្នុងសម័យប្រជុំលើកទី៧៦ នៃមហាសន្និបាតអង្គការសន្និបាតUNនៅទីក្រុងញ៉ូវយ៉ក សហរដ្ឋអាមេរិក ថ្ងៃទី២១ ខែកញ្ញា ឆ្នាំ ២០២១ រូបថតដោយ៖ Reuters/Eduardo Munoz/Pool*

កំណើនពាណិជ្ជកម្មពិភពលោកមានស្ថិរភាពនៅក្នុងឆមាសទី២ ឆ្នាំ២០២១ ប៉ុន្តែទស្សនៈវិស័យសម្រាប់ឆ្នាំ ២០២២ ហាក់មានភាពមិនច្បាស់លាស់កាន់តែខ្លាំងនេះបើយោងសេចក្តីប្រកាសនៅក្នុងសន្និសីទអង្គការសហប្រជាជាតិស្តីពីពាណិជ្ជកម្ម និងការអភិវឌ្ឍន៍ ហៅកាត់ UNCTAD កាលពីថ្ងៃព្រហស្បតិ៍កន្លងទៅ។

ពាណិជ្ជកម្មអន្តរជាតិនៅក្នុងឆ្នាំ២០២១ មានភាពវិជ្ជមានដោយសារតែការងើបឡើងវិញនៃតម្រូវការ និងវិធានការរឹតបន្តឹងចំពោះការទប់ស្កាត់លើការរីករាលដាលជំងឺកូវីដ ១៩ មានការបន្ធូរបន្ថយច្រើនជាងមុន ចំណែកឯកញ្ចប់ជំរុញសេដ្ឋកិច្ច និងថ្លៃទំនិញមានការកើនឡើង។ ប៉ុន្តែទោះជាយ៉ាងណា ការព្យាករណ៍សម្រាប់ឆ្នាំ ២០២២ មានភាពមិនប្រាកដប្រជាខ្លាំង។ *ដោយ វង្ស ច័ន្ទរស្មីដារា ប្រភព៖ Reuters ចេញផ្សាយថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២១*

### កូវីដបំប្លែងថ្មីOmicronគំរាមកំហែងសេដ្ឋកិច្ចអាមេរិក និងពិភពលោក



*តម្រូវការរបស់អ្នកប្រើប្រាស់ក្នុងផ្សារវិស្សមកាល Manhattan អាចនឹងធ្លាក់ចុះ ដោយសារតែកូវីដបំប្លែងថ្មី Omicron។ រូបថតដោយ៖ JEENAH MOON FOR THE WALL STREET JOURNAL*

ការវិវត្តរបស់ជំងឺកូវីដ១៩ ប្រភេទថ្មី Omicron អាចនឹងធ្វើឱ្យសេដ្ឋកិច្ចរបស់ពិភពលោកមានកំណើនយឺត ប៉ុន្តែផលប៉ះពាល់ទំនងជាមានកម្រិតតិចតួច។ ក្នុងនោះ ចំណាយលើវិស័យទេសចរណ៍ និងការចំណាយលើវិស័យភោជនីយដ្ឋាន ក៏ដូចជាការដើរផ្សារទិញទំនិញទំនងជានឹងធ្លាក់ចុះ។

ប៉ុន្តែបើប្រៀបធៀបជាមួយរលកទី១ របស់ជំងឺកូវីដ១៩ ដែលបានផ្ទុះលើកដំបូងក្នុងខែមីនា ឆ្នាំ២០២០ និងរលកកូវីដ១៩ ប្រភេទថ្មី Delta ដែលបានផ្ទុះឡើងកាលពីរដូវក្តៅកន្លងទៅ ការគំរាមកំហែងរបស់កូវីដ១៩ ប្រភេទថ្មី Omicron ចំពោះសេដ្ឋកិច្ចទំនងជាមិនសូវជាធ្ងន់ធ្ងរប៉ុន្មានទេ ពីព្រោះផលប៉ះពាល់របស់កូវីដ១៩ ប្រភេទនីមួយៗ តែងតែថមថយឥទ្ធិពលទៅវិញ។ ជាក់ស្តែងសេដ្ឋកិច្ចរបស់សហរដ្ឋអាមេរិក និងពិភពលោកមានសន្ទុះងើបឡើងវិញ បន្ទាប់ពីរដ្ឋាភិបាលនានាចាត់វិធានការឆ្លើយតបចំពោះផលប៉ះពាល់ចំពោះសេដ្ឋកិច្ច

ដើម្បីជម្រុញសកម្មភាពសេដ្ឋកិច្ច និងតម្រូវការ ជាពិសេសនៅសហរដ្ឋអាមេរិក។

ម្យ៉ាងវិញទៀត បញ្ហានៅក្នុងខ្សែសង្វាក់ផ្គត់ផ្គង់ដែលកម្រិតដល់កំណើនសេដ្ឋកិច្ច ក្នុងអំលុងពេលថ្មីៗនេះហាក់មានសញ្ញាណធូរស្រាលឡើងវិញ។ លើសពីនោះអត្រាកំណើននៃការចាក់វ៉ាក់សាំង នៅក្នុងដើមឆ្នាំនេះមានកំណើនខ្ពស់អាចជួយកាត់បន្ថយដល់ហានិភ័យចំពោះសុខភាព ដែលបង្ករឡើងដោយជំងឺកូវីដ១៩ប្រភេទថ្មី Omicron។

លើសពីនោះរដ្ឋាភិបាលនៅក្នុងប្រទេសផ្សេងៗទំនងជាមិនសូវចាត់វិធានការបិតខ្ទប់ដូចជាការរាតត្បាតជំងឺកូវីដ ១៩ មុនៗទេ។ សូម្បីតែរដ្ឋាភិបាលសហរដ្ឋអាមេរិកបច្ចុប្បន្នក៏ផ្តោតលើការចាក់វ៉ាក់សាំងជាងស្វែងរកវិធានការថ្មីៗដើម្បីរឹតបន្តឹងសកម្មភាពពាណិជ្ជកម្មដែរ។ ទោះយ៉ាងណា សេដ្ឋវិទូបានព្យាករណ៍ឃើញថា ជំងឺកូវីដ ១៩ ប្រភេទថ្មី Omicron អាចនឹងធ្វើឱ្យកំណើនសេដ្ឋកិច្ចនៅក្នុងត្រីមាសនេះ និងកំណើនសេដ្ឋកិច្ចនៅឆ្នាំក្រោយមានកំណើនយឺត ប៉ុន្តែផលប៉ះពាល់របស់វាមិនអាចធ្វើឱ្យសេដ្ឋកិច្ចពិភពលោកមានកំណើនថយបានទេ។

សេដ្ឋវិទូនៅសាកលវិទ្យាល័យ Oxford បានព្យាករណ៍ថា ផ.ស.ស របស់សាកលលោកអាចនឹងមានកំណើន ៤,២ភាគរយ នៅក្នុងឆ្នាំ ២០២២ ទាបជាងការព្យាករណ៍លើកមុនដែលបានរំពឹងថា សេដ្ឋកិច្ចពិភពលោកនៅក្នុងឆ្នាំ២០២២ អាចនឹងមានកំណើន ៤,៥ ភាគរយ។ សេដ្ឋវិទូបានពន្យល់ថា គេអាចវាស់វែងការខូចខាត និងទំហំនៃផលប៉ះពាល់ចំពោះសេដ្ឋកិច្ចបានអាស្រ័យលើចំនួនមនុស្សដែលឆ្លង និងចំនួនមនុស្សដែលបានស្លាប់ និងផ្អែកលើការឆ្លើយតបរបស់រាជរដ្ឋាភិបាល អ្នកប្រើប្រាស់ និងអាជីវកម្មនានាចំពោះផលប៉ះពាល់នោះ។

មួយវិញទៀត បើផ្អែកលើវិភាគចំពោះផលប៉ះពាល់លើផ្នែកផ្គត់ផ្គង់ (supply side) ផលរំខានចំពោះការផ្គត់ផ្គង់អាចបន្តតម្រូវឱ្យកម្មករធ្វើការពីផ្ទះ ដែលជាហេតុនាំឱ្យផលិតភាពរបស់រោងចក្រមានកម្រិត និងមិនអាចឆ្លើយតបចំពោះតម្រូវការ។ ជាលទ្ធផល ស្ថានភាពនេះអាចនឹងធ្វើឱ្យមានផលរំខានដល់បណ្តាញផ្គត់ផ្គង់នៅក្នុងសាកលលោក និងបង្ករឱ្យហានិភ័យចំពោះអតិផរណាកាន់តែមានការប្រឈមខ្លាំងជាងមុន។ ព្រោះអត្រាអតិផរណានៅសហរដ្ឋអាមេរិកក្នុងអំលុងបីទស្សវត្សន៍កន្លងមកនេះមានកម្រិតខ្ពស់រួចស្រាប់ទៅហើយ។ ខណៈដែលអត្រាអតិផរណានៅតាមបណ្តាប្រទេសផ្សេងៗមួយចំនួនទៀតក៏មានកម្រិតខ្ពស់ដែរ ដោយសារតែតម្រូវការកើនឡើង ប៉ុន្តែការផ្គត់ផ្គង់បែរជាថយចុះ។ សរុបមក Omicron ធ្វើឱ្យអតិផរណាមានភាពមិនច្បាស់លាស់ និងបង្ករឱ្យមានហានិភ័យដល់សេដ្ឋកិច្ចរបស់ប្រទេសទាំងអស់នៅក្នុងពិភពលោក។ ព្រោះប្រសិនបើ Omicron រំខានដល់ការផ្គត់ផ្គង់ នោះថ្លៃទំនិញ និងសេវាកម្មនឹងកើនឡើង ឬថ្លៃជាងមុន។ ប៉ុន្តែប្រសិនបើតម្រូវការធ្លាក់ចុះ នោះតម្លៃប្រេងក៏នឹងធ្លាក់ចុះដែរ។ លោក Craig Botham ប្រធានសេដ្ឋវិទូចិននៅ Pantheon Macroeconomics ដែលមានទីស្នាក់ការនៅទីក្រុងលុងបាននិយាយថា អាជីវកម្មនានា និងវិនិយោគិន គួរតែត្រៀមខ្លួនឱ្យបានរួចជាស្រេច ដើម្បីឆ្លើយតបចំពោះបញ្ហាមួយចំនួនដែលមិនអាចស្មានដឹងមុនដូចជា៖ ការបិតរោងចក្រ និងកំពង់ផែរបស់ប្រទេសចិន និងប្រសិនបើរដ្ឋាភិបាលចាត់វិធានការរឹតបន្តឹងកាន់តែតឹងរឹងបន្ថែមទៀតលើវិស័យសេវាកម្ម និងសកម្មភាពសេដ្ឋកិច្ចចល័តនានា៕ *ដោយ វង្ស ច័ន្ទរស្មីដារា*

*ប្រភព៖ The Wall Street Journal ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២១*

## OPEC+ ទំនងជាមានភាពប្រុងប្រយ័ត្នខ្លាំងចំពោះផែនការបង្កើនទិន្នផលប្រេងនៅកិច្ចប្រជុំសប្តាហ៍នេះ




អង្គការ OPEC និងប្រទេសសម្ព័ន្ធមិត្ត មានភាពប្រយ័ត្នប្រយែង ថាតើត្រូវរក្សាផែនការបង្កើនទិន្នផលប្រេងនៅដដែលឬអត់ បន្ទាប់ពីការកើតមានវីរុសកូរ៉ូណាប្រភេទថ្មី ដែលបង្កឱ្យប្រេងធ្លាក់ថ្លៃ។ តម្រូវការកំពុងធ្លាក់ចុះនៅក្នុងទីផ្សារមួយចំនួននៅរដូវត្រជាក់ខាងមុខនេះនៅតំបន់អាស៊ី និងអឺរ៉ុប ហើយមេរោគកូរ៉ូណាប្រភេទថ្មី នឹងធ្វើឱ្យមានការលុបចោលជើងហោះហើរកាន់តែច្រើន។ ប្រេងឆៅប្រភេទ WTI របស់អាមេរិកបានធ្លាក់ថ្លៃជាង ១០%(ក្រោម៧០ដុល្លារក្នុងមួយបារ៉ែល)នៅសប្តាហ៍មុន ដែលជាការធ្លាក់លើកដំបូងគិតចាប់ពីខែកញ្ញាមក ហើយប្រភេទឆៅប្រភេទ Brent របស់អង់គ្លេសបានធ្លាក់ចុះខ្លាំងដោយសារព័ត៌មានអំពីមេរោគកូរ៉ូណាប្រភេទថ្មីឈ្មោះ អូមីក្រុង ប៉ះពាល់ដល់អារម្មណ៍វិនិយោគិន។ ក្រុមប្រទេសផលិតប្រេង OPEC+ បានសម្តែងក្តីបារម្ភរួចហើយជុំវិញការផ្គត់ផ្គង់លើស ព្រោះអាមេរិកនិងប្រទេសផ្សេងទៀតប្រកាសផែនការបញ្ចេញប្រេងពីស្តុកយុទ្ធសាស្ត្ររបស់ខ្លួន។

ក្រុមប្រទេសជាសមាជិករបស់អង្គការ OPEC និងប្រទេសជាដៃគូដូចជាប្រទេសរុស្ស៊ី ហៅថា OPEC+ គ្រោងជួបប្រជុំនៅសប្តាហ៍នេះ ដើម្បីពិចារណា ថាតើត្រូវអនុវត្តផែនការបង្កើនទិន្នផលប្រេងចំនួន ៤សែនបារ៉ែលក្នុងមួយថ្ងៃ ឬយ៉ាងណា។ ក្រុមប្រទេសទាំងនេះបាននិងកំពុងបញ្ជូនប្រេងឆៅយឺតៗចូលក្នុងទីផ្សារពិភពលោក។ ក្រុមប្រទេស OPEC+ នឹងជួបប្រជុំពិភាក្សាគ្នាអំពីផលិតកម្មសម្រាប់ខែមករា អាចផ្អាកការបង្កើន ទិន្នផលប្រេងប្រចាំខែ ដោយសារតម្រូវការប្រែប្រួល ហើយសមាជិកមួយចំនួនចង់អនុវត្តវិធីសាស្ត្រនេះ៕ *ដោយ ម៉ែន ខេមរៈ*

*ប្រភព ៖ freshnews ចេញផ្សាយថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២១។*

## ទិន្នន័យស្រាវជ្រាវសម្រាប់សប្តាហ៍បន្ទាប់

ថ្ងៃចន្ទ ទី០៦ ខែធ្នូ ឆ្នាំ២០២១

- កំណើននៃការលក់រាយនៅក្នុងប្រទេសអ៊ីតាលី ក្នុងខែកញ្ញា ឆ្នាំ 2021
- កំណើននៃទំនុកចិត្តរបស់អតិថិជននៅម៉ិកស៊ិក បានកើនឡើង ក្នុងខែតុលា ឆ្នាំ 2021 ធៀបក្នុងខែមុន

ថ្ងៃអង្គារ ទី០៧ ខែធ្នូ ឆ្នាំ២០២១

- អតិរេកពាណិជ្ជកម្មរបស់ប្រទេសចិន បានកើនឡើងដល់កម្រិតខ្ពស់បំផុត ក្នុងខែតុលា ឆ្នាំ 2021
- កំណើននៃឱនភាពពាណិជ្ជកម្មរបស់ប្រទេសបារាំង បានពង្រីកដល់ 6.78 ពាន់លានអឺរ៉ូក្នុងខែកញ្ញា ឆ្នាំ 2021

ថ្ងៃពុធ ទី០៨ ខែធ្នូ ឆ្នាំ២០២១

- កំណើននៃឱនភាពពាណិជ្ជកម្មរបស់សហរដ្ឋអាមេរិក បានកើនឡើងដល់កម្រិតខ្ពស់បំផុតក្នុងខែកញ្ញា ឆ្នាំ 2021
- កំណាលនអត្រាអតិផរណាប្រចាំឆ្នាំ របស់រុស្ស៊ី បានកើនឡើងដល់ 8.13%ក្នុងខែតុលា ឆ្នាំ 2021 ពី 7.4%នៅក្នុងខែកញ្ញា

ថ្ងៃព្រហស្បតិ៍ ទី០៩ ខែធ្នូ ឆ្នាំ២០២១

- អតិរេកពាណិជ្ជកម្មនៅប្រទេសអាឡឺម៉ង់ បានរួមតូច ក្នុងខែកញ្ញា ឆ្នាំ 2021
- ការផ្លាស់ប្តូរជាមធ្យមរយៈពេល4សប្តាហ៍នៃការទាមទារគ្មានការងារធ្វើរបស់សហរដ្ឋអាមេរិក បានធ្លាក់ចុះ នៅខែវិច្ឆិកា

ថ្ងៃសុក្រ ទី១០ ខែធ្នូ ឆ្នាំ២០២១

- អត្រានីកម្មភាព តាមរដូវកាលនៅក្នុងប្រទេសទួរគីបានធ្លាក់ចុះ ក្នុងខែកញ្ញា ឆ្នាំ 2021
- កំណើនផលិតកម្មឧស្សាហកម្មរបស់ប្រទេសម៉ិកស៊ិក បានកើនឡើង ក្នុងខែកញ្ញា ឆ្នាំ 2021៕